# តំណឹងថ្មីនៃការតភ្ជាប់ជាថ្មីនៃតំបន់ខាងលិចក្រុងសៀអាថុល

ទំព័រអង្គហេតុ

**ខែធ្នូ ឆ្នាំ២០២០**

## ស្ពានខ្ពស់ខាងលិចក្រុងសៀអាថុលបើកប្រើប្រាស់ឡើងវិញក្នុងឆ្នាំ ២០២២

នៅខែមីនា ឆ្នាំ២០២០ ដើម្បីជាផលប្រយោជន៍សុវត្ថិភាពសាធារណៈ នាយកដ្ឋានដឹកជញ្ជូនទីក្រុងសៀអាថុល (SDOT) បានបិទស្ពានខ្ពស់តំបន់ខាងលិចក្រុងសៀអាថុលសម្រាប់រាល់ចរាចរណ៍យានយន្ត។ នៅខែវិច្ឆិកា ឆ្នាំ២០២០ ធ្វើការជាមួយនាយកដ្ឋានដឹកជញ្ជូនទីក្រុងសៀអាថុលនិងសហគមន៍ អ្នកស្រីអភិបាលក្រុង Jenny Durkan បានធ្វើការសំរេចចិត្តជួសជុលស្ពាននេះ។ ស្ពាននេះត្រូវបានរំពឹងថានឹងបើកដំណើរការឡើងវិញនៅក្នុងឆ្នាំ ២០២២ ។




យើងកំពុងធ្វើការតភ្ជាប់ឡើងវិញទៅភាគខាងលិចទីក្រុងសៀអាថុលនិងធ្វើឱ្យចរាចរណ៍ស្ងប់ស្ងាត់នៅក្នុងសង្កាត់ដែលរងផលប៉ះពាល់បំផុតដោយការបិទនេះ។




ដើរ ជិះកង់ ជិះម៉ូតូ ឬម៉ូតូខ្នាតតូច ដើម្បីកាត់បន្ថយការកកស្ទះចរាចរណ៍។

### ការធ្វើដំណើររបស់អ្នកប៉ះពាល់ដល់អ្នករាល់គ្នា

ខណៈពេលដែលស្ពាននៅបិទ អ្នករាល់គ្នាត្រូវរួមចំណែកធ្វើផ្នែករបស់ខ្លួនដើម្បីកាត់បន្ថយផលប៉ះពាល់ក្នុងការធ្វើដំណើររបស់ខ្លួន។ បើអាច សូមរកជម្រើសផ្សេងទៀតដើម្បីទៅដល់គោលដៅរបស់អ្នក៖

- ដើរ ជិះកង់ ជិះម៉ូតូ ឬម៉ូតូខ្នាតតូច
- ជិះឡានក្រុងឬតាក់ស៊ីលើទឹក
- ជិះឡានក្រុមឬឡានរួមគ្នា
- នៅនិងទិញអ្វីៗក្នុងតំបន់របស់អ្នក

ជម្រើសទាំងនេះអាចជួយកាត់បន្ថយការកកស្ទះនិងការពារសុខភាពប្រជាជនដែលរស់នៅក្នុងសហគមន៍ដែលរងផលប៉ះពាល់។ ប្រសិនបើអ្នកបើកបរ សូមជួយពួកយើងអោយអ្នកជិតខាងមានសុវត្ថិភាពដោយបើកបរតាមកម្រិតល្បឿនដែលបានបោះកំណត់តាមបណ្តោយផ្លូវវាងទាំងអស់នេះ។ ដើម្បីទទួលបានគំនិតនិងធនធានក្នុងការធ្វើដំណើរទាក់ទងនឹងការបិទនេះ សូមចូលមើលក្នុងគេហទំព័ររបស់យើង។


**ព័ត៌មានអំពីគំរោងនិងការទំនាក់ទំនង**

WestSeattleBridge@seattle.gov | (២០៦) ៤០០-៧៥១១

www.seattle.gov/ReconnectWestSeattle

Seattle Department of Transportation

## ការផាកពិន័យនៃស្ពានទាបនឹងចាប់ផ្តើមក្នុងខែមករា ឆ្នាំ២០២១

បច្ចុប្បន្នស្ពានទាបបើកអោយយានយន្តឯកជនប្រើប្រាស់បានតែពេលយប់ប៉ុណ្ណោះ (៩ យប់ - ៥ ព្រឹក) ។ ចំពោះពេលពេលវេលាទាំងអស់ដទៃទៀត គឺបើកអោយប្រើប្រាស់សម្រាប់តែរថយន្តសង្គ្រោះបន្ទាន់ រថយន្តដឹកទំនិញធុនធំ ឡានក្រុង និងរថយន្តដែលមានការអនុញ្ញាតតែប៉ុណ្ណោះ។



**ចាប់ផ្តើមពីខែមករាឆ្នាំ ២០២១ យានយន្តឯកជនដែលបើកបរលើស្ពានចាប់ពីម៉ោង ៥ ព្រឹក ដល់ម៉ោង ៩ យប់ នឹងត្រូវពិន័យ ៧៥ ដុល្លារ សម្រាប់ការធ្វើដំណើរនីមួយៗ។**

សូមរៀបចំផែនការទៅតាមបែបបទនេះ។

ស្វែងយល់ព័ត៌មានបន្ថែម៖
www.seattle.gov/transportation/LowBridge



ស្ពានទាបមើលទៅខាងកើត

## ២០២១ ការកែលំអរសង្កាត់ក្នុងសហគមន៍

### ការកែលំអរផ្លូវ W MARGINAL WAY SW

យើងកំពុងចាប់ផ្តើមផ្សព្វផ្សាយនិងចូលរួមនៅក្នុងខែនេះដើម្បីធ្វើឱ្យផ្លូវ W Marginal Way SW មានសុវត្ថិភាពនិងអាចដំណើរការបានល្អសម្រាប់អ្នករាល់គ្នា។

### ការធ្វើផែនការតំបន់ផ្ទះ

យើងកំពុងធ្វើការជាមួយ Georgetown, South Park និង Highland Park ដែលជាសង្កាត់ដែលរងផលប៉ះពាល់ខ្លាំងដោយបង្កើតផ្លូវវាងសំរាប់ចរាចរណ៍ ដើម្បីបង្កើតផែនការសម្រាប់តំបន់ផ្ទះសម្រាប់សង្កាត់នីមួយៗ។ តំបន់ផ្ទះពាក់ព័ន្ធនឹងសង្កាត់ទាំងមូលគឺធ្វើការរួមគ្នាដើម្បីផ្តល់អាទិភាពលើការកែលំអរដែលធ្វើឱ្យចរាចរណ៍ស្ងប់ស្ងាត់ និងធ្វើឱ្យប្រសើរឡើងនូវភាពចល័តរបស់អ្នកថ្មើរជើងនិងភាពរស់នៅរបស់អ្នកជិតខាងក្នុងតំបន់។

ដើម្បីស្វែងយល់បន្ថែមនិងផ្តល់យោបល់សូមចូលទស្សនានៅក្នុងគេហទំព័ររបស់យើង៖
www.seattle.gov/ReconnectWestSeattle ។




ផ្លូវខ្វែង SW Spokane St និងផ្លូវ W Marginal Way SW



យើងប្តេជ្ញាថានឹងជូនដំណឹងដល់អ្នកក្នុងកំឡុងពេលបិទស្ពានខ្ពស់នៅភាគខាងលិចទីក្រុងសៀអាថុល។

### សូមទាក់ទងមកយើង

យើងប្តេជ្ញាថានឹងជូនដំណឹងដល់អ្នកអំពីការរីកចម្រើននិងព្រឹត្តិការណ៍សំខាន់ៗ នៅពេលដែលយើងជួសជុលស្ពាន។ យើងនឹងស្វែងរកមតិយោបល់បន្តអំពីអ្នកដើម្បីកែលម្អក្នុងការធ្វើដំណើរនិងសុវត្ថិភាព។

- **សូមហៅយើងចូលរួមជួបប្រជុំតាមអិធីណិត**ជាមួយក្រុមឬអង្គការរបស់អ្នក
- **សូមផ្ញើសារឬទូរសព្ទមកយើង**ដើម្បីចែករំលែកគំនិតរបស់អ្នក: WestSeattleBridge@seattle.gov ឬ(២០៦) ៤០០-៧៥១១
- **សូមចូលមើលគេហទំព័ររបស់យើង** ដើម្បីចុះឈ្មោះទទួលសារដំណឹងថ្មីៗប្រចាំសប្តាហ៍: www.seattle.gov/ReconnectWestSeattle

**ព័ត៌មានអំពីគំរោងនិងការទំនាក់ទំនង**
WestSeattleBridge@seattle.gov | **(២០៦) ៤០០-៧៥១១**
www.seattle.gov/ReconnectWestSeattle

Seattle Department of Transportation